**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ពិធីសម្ពោធចំណតផែពហុបំណង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) សូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា៖ នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៨ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវចំណតផែពហុបំណង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ចំណតផែពហុបំណងនេះ សាងសង់រួមមាន៖ ចំណតផែទំនិញរាយប្រវែង ៣៣០ម៉ែត ជម្រៅទឹក ១៣,៥ម៉ែត ចំណតផែមូលដ្ឋានផ្គត់ផ្គង់ភស្តុភារសម្រាប់ការរុករកប្រេងប្រវែង២០០ម៉ែត្រ ជម្រៅទឹក ៧,៥ម៉ែត្រ និងការផ្គត់ផ្គង់នាវាសណ្តោង(Tugboat) សមត្ថភាព ៣.២០០សេះ ១គ្រឿង ក្រោមហិរញ្ញប្បទានសម្បទានមានទឹកប្រាក់សរុបប្រហាក់ប្រហែល ៧៤លាន ដុល្លារអាមេរិកពីរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ។ ទន្ទឹមនឹងនេះ ចំណតផែននេះ អាចអនុញ្ញាតឲ្យនាវាដឹកទំនិញរាយកាន់តែធំជាងមុនមានចំណុះផ្ទុកដល់ ៥០ពាន់តោន អាចចូលចតបាន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន ។

ថ្ងៃ អង្គារ ១៤កើត ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២
ខេត្តព្រះសីហនុ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N° 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh